ព្រះរាជាណាចក្រ កម្ពុជា
Kingdom of Cambodia

ជាតិ សាសនា ព្រះមហាក្សត្រ
Nation Religion King

រាជរដ្ឋាភិបាល កម្ពុជា
Royal Government of Cambodia

លេខ: ៣៩ សសរ.

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតគណៈកម្មការជាតិយូណេស្កូកម្ពុជា

* * * * *

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រិត្យ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងនាយករដ្ឋមន្ត្រីទី ១ និង នាយករដ្ឋមន្ត្រីទី ២ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រិត្យ ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្ដីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រិត្យលេខ នស/រកត១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រិត្យលេខ នស/រកត១០៩៤/៩០ ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ១៩៩៤ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រិត្យលេខ ជស/រកត០៨៩៧/១៤៧ ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ១៩៩៧ ស្ដីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- យោងតាមសំណើក្រសួងការបរទេស ចុះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៩៧

## សំរេច

ប្រការ ១ : បង្កើតគណៈកម្មការមួយមានឈ្មោះថា "គណៈកម្មការជាតិ យូណេស្កូកម្ពុជា" ដែលមានសមាសភាពដូចតទៅ ៖

RELEX

Scanned with CamScanner

១-ឯកឧត្តម សុខ អាន
សហាវដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី - ប្រធាន
២-ឯកឧត្តម អ៊ុច ស៊ាន អនុរដ្ឋលេខាធិការក្រសួងការបរទេស តំណាងក្រសួង
ការបរទេស និង សហប្រតិបត្តិការអន្តរជាតិ អគ្គលេខាធិការ
៣-លោក យ៉ង់ យ៉ាណុ អនុប្រធានមន្ទីរក្រសួងអប់រំ តំណាងក្រសួងអប់រំ
យុវជន និង កីឡា អគ្គលេខាធិការរង
៤-លោក ជុច តៀន សកលវិទ្យាធិការរង ក្រសួងវប្បធម៌ និង សិល្បៈ
តំណាងក្រសួង វប្បធម៌ និង សិល្បៈ អគ្គលេខាធិការរង
៥-លោក មួង សុទត្តិ ប្រធាននាយកដ្ឋានក្រសួងព័ត៌មាន តំណាងក្រសួងព័ត៌មាន សមាជិក

ប្រការ ២ : គណៈកម្មការជាតិ យូណេស្កូកម្ពុជា មានភារកិច្ចដូចតទៅ ៖

- ផ្តល់យោបល់ជូនរាជរដ្ឋាភិបាលស្តីពីបញ្ហាទាំងឡាយ ដែលទាក់ទងនឹងយូណេស្កូ និង កម្មវិធីរបស់ យូណេស្កូ ។
- មានតួនាទីជាភ្នាក់ងារទាក់ទងរវាងយូណេស្កូជាមួយក្រសួង ស្ថាប័ន អង្គការ និងបុគ្គលនានាដែលយកចិត្តទុកដាក់បំពេញការងារ ដើម្បីជំរុញឱ្យមានការរីកចំរើនផ្នែកអប់រំ វិទ្យាសាស្ត្រ វប្បធម៌ និង ព័ត៌មាននៅកម្ពុជា ។
- ធានានូវការចូលរួមយ៉ាងសកម្មរបស់កម្ពុជា ក្នុងកម្មវិធីចូលរួមជាមួយគ្នារបស់យូណេស្កូ ដោយធ្វើការសម្របសម្រួលជ្រើសរើសគំរោងអាទិភាពទាំងឡាយ រៀបចំដោយក្រសួង និង ស្ថាប័នពាក់ព័ន្ធនានា ។
- ជួយរាជរដ្ឋាភិបាលក្នុងការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និង អង្គការពាក់ព័ន្ធនានាអំពីការជ្រើសរើសបេក្ខជនសំរាប់កម្មវិធីអាហារូបករណ៍ ។
- ជួយរដ្ឋាភិបាលក្នុងការរៀបចំ និង ការចូលរួមសម័យប្រជុំសន្និសីទទូទៅ និង ការប្រជុំអន្តររដ្ឋាភិបាលផ្សេងៗទៀតដែលរៀបចំដោយយូណេស្កូ ។
- ជម្រុញ និង ពង្រីកទំនាក់ទំនងជាមួយគណៈកម្មការជាតិយូណេស្កូផ្សេងទៀត ជាពិសេសជាមួយគណៈកម្មការជាតិយូណេស្កូនៅក្នុងតំបន់ជាមួយគ្នា និង ចូលរួមជាមួយគណៈកម្មការទាំងនោះ ក្នុងកម្មវិធីរួមគ្នា និង សិក្សាអំពីបញ្ហាទាំងឡាយ ដែលមានប្រយោជន៍ដល់ព្រះរាជាណាចក្រកម្ពុជា ។
- បំពេញភារកិច្ចដទៃទៀត ដែលត្រូវបានកំណត់ដោយរាជរដ្ឋាភិបាលកម្ពុជា ដែលពាក់ព័ន្ធដល់ គណៈកម្មការយូណេស្កូកម្ពុជា និង គណៈកម្មការយូណេស្កូតំបន់ និង យូណេស្កូរួម ។

ប្រការ ៣ : គណៈកម្មការជាតិមានសិទ្ធិរៀបចំមហាសន្និបាតយ៉ាងតិចមួយដងក្នុងមួយឆ្នាំ ដឹកនាំដោយប្រធាន ឬ អនុប្រធាន និង ការប្រជុំដទៃទៀតតាមការយល់ឃើញរបស់ប្រធាន ឬតាមការស្នើសុំពី សមាជិកភាគច្រើនរបស់គណៈកម្មការជាតិ ។

Scanned with CamScanner

**មហាសន្និបាតមានភារកិច្ច :**

-អនុម័តរបាយការណ៍ប្រចាំឆ្នាំ ណែនាំ និង ចាត់វិធានការចំពោះអភិវឌ្ឍន៍កម្មវិធី និង សកម្មភាពរបស់គណៈកម្មការជាតិយូណេស្កូបន្តទៅមុខទៀត ។

-លើកសំណើអំពីការជ្រើសរើសសមាសភាពគណៈប្រតិភូកម្ពុជា ទៅចូលរួមសន្និសីទទូទៅរបស់ យូណេស្កូ ជូនរាជរដ្ឋាភិបាល ។

ប្រការ ៤ : គណៈកម្មការជាតិយូណេស្កូកម្ពុជា មានសិទ្ធិបង្កើតអនុគណៈកម្មការជំនាញមួយចំនួនទៀត និង លេខាធិការដ្ឋានអចិន្ត្រៃយ៍ ដើម្បីអនុវត្តការងារ ។ តួនាទី និង ភារកិច្ចរបស់អនុ-គណៈកម្មការ និង លេខាធិការដ្ឋានអចិន្ត្រៃយ៍ត្រូវកំណត់ដោយឡែក ដោយគណៈកម្មការជាតិយូណេស្កូកម្ពុជា ។

ប្រការ ៥ : គណៈកម្មការជាតិយូណេស្កូកម្ពុជា មានទីស្នាក់ការបណ្ដោះអាសន្ននៅទីស្នាក់ការគណៈរដ្ឋមន្ត្រី និង មានសិទ្ធិប្រើប្រាស់ត្រារបស់គណៈរដ្ឋមន្ត្រី ។

ប្រការ ៦ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី ក្រសួង ស្ថាប័ន ឯកឧត្តម ដូចប្រការ ១ និង ក្រសួងស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុក អនុវត្តតាមខ្លឹមសារនៃសេចក្ដីសំរេចនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។៚

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ៧ ឆ្នាំ ១៩៩៧

**នាយករដ្ឋមន្ត្រីទី ១** **នាយករដ្ឋមន្ត្រីទី ២**

អ៊ុង ហួត ហ៊ុន សែន